# ចម្លាក់ប្រយុទ្ធគ្នារវាងសុន្ទ និងឧបសុន្ទ

រឿងមហាភារត ជារឿងរៀបរាប់ពីការធ្វើសង្គ្រាមរវាងគ្រួសាររាជវង្សពីរក្រុម គឺបណ្ឌវ និងកុរវ ដែលទាំងពីរក្រុមជាបងប្អូនជីដូនមួយនឹងគ្នា ដើម្បីអំណាច។ រឿងនេះមានឥទ្ធិពលខ្លាំងមកលើសិល្បៈខ្មែរនាសម័យបុរាណដែលស្តែងចេញតាមរយៈចម្លាក់ និងបដិមាទោលជាដើម។ យ៉ាងណាមិញ មានឈុតតូចមួយក្នុងរឿងមហាភារតរៀបរាប់ពីសុន្ទ (Sunda) និងឧបសុន្ទ (Upasunda) ជាអសុរ២នាក់ត្រូវជាបងប្អូននឹងគ្នា ហើយមានមហិទ្ធឫទ្ធិ អំណាចខ្លាំងពូកែដែលបង្កភាពចលាចលដល់ស្ថានទាំងបី។ ពួកគេទាំងពីរមានក្តីស្រមៃដណ្តើមយកស្ថានទាំងបីមកកាន់កាប់។ ក្នុងសិល្បៈខ្មែរក៏មានបង្ហាញឈុតប្រយុទ្ធគ្នារវាងសុន្ទ និងឧបសុន្ទមួយចំនួនដែរ ជាពិសេសនៅលើហោជាង។ តើដំណើររឿង និងចម្លាក់បង្ហាញពីការប្រយុទ្ធគ្នារវាងប្អូនទាំងពីរនាក់នេះមានលក្ខណៈដូចម្តេចខ្លះ?

ដំណើររឿងក្នុងឈុតនេះនិទានថា៖ មានបងប្អូនពីរនាក់ឈ្មោះសុន្ទ និងឧបសុន្ទ ជាកូនប្រុសរបស់ និកុភ ព្រមទាំងជាគ្នារបស់ ហិរណ្យកសិបុ។ ពួកគេត្រូវបំពេញភារកិច្ចរួមគ្នាដើម្បីគ្រប់គ្រងស្ថានទាំងបី ហើយមិនអាចរស់នៅដោយគ្មានគ្នាបានឡើយ។ អសុរទាំងពីរបានតាំងចិត្តអនុវត្តន៍ភារកិច្ចទោះបីជាមានឧបសគ្គយ៉ាងណាក៏ដោយ។ ដោយសារការខិតខំរបស់ពួកគេ ធ្វើឱ្យព្រះព្រហ្មមើលឃើញ ក៏បំពេញបំណងប្រាថ្នារបស់ពួកគេ គឺទ្រង់បានផ្តល់អំណាច និងមហិទ្ធិឫទ្ធិខ្លាំងពូកែ ប៉ុន្តែព្រះព្រហ្មមិនបានផ្តល់ជីវិតអមតៈដល់ពួកគេទេ។ ចុងក្រោយ ពួកគេក៏សុំពរពីទ្រង់ថា "គ្មាននរណាអាចសម្លាប់ពួកគេបានឡើយ សូម្បីតែទេព ឬអសុរក៏ដោយ គឺមានតែម្នាក់ក្នុងចំណោមបងប្អូនគេទាំងពីរប៉ុណ្ណោះដែលអាចសម្លាប់គ្នាបាន។ ពួកគេសុំពរបែបនេះដោយសារតែពួកគេគិតថា ពួកគេទាំងពីរស្រឡាញ់គ្នា មិនអាចសម្លាប់គ្នាបានឡើយ។ ព្រះព្រហ្មក៏យល់ព្រមតាមការស្នើសុំនេះ។ បន្ទាប់ពីបានពរពីព្រះព្រហ្មហើយ ពួកគេទាំងពីរក៏ដើរធ្វើបាបទេព និងពួកព្រាហ្មណ៍ ព្រមទាំងយកឈ្នះ ហើយគ្រប់គ្រងស្ថានទាំងបី។ ក្រោយមក ទេពទាំងឡាយ ពួកព្រាហ្មណ៍ មនុស្សម្នាមិនអាចទ្រាំនឹងទង្វើអាក្រក់របស់អសុរទាំងពីរនេះបានទៀត ក៏មូលមតិគ្នាពឹងព្រះវិស្វកម្មឱ្យបង្កើតនារីម្នាក់មានសម្រស់ស្រស់ស្អាតឈ្មោះថា "តិលោត្តមា" ឱ្យទៅរកសុន្ទ និងឧបសុន្ទ ក្នុងគោលបំណងពង្វក់បងប្អូនទាំងពីរឱ្យឈ្លោះគ្នាដណ្តើមនាង។ ដោយសារភ្លេចពរពីព្រះព្រហ្ម ពួកគេទាំងពីរនាក់ក៏ប្រយុទ្ធគ្នាដណ្តើមនាងតិលោត្តមា រហូតដល់ស្លាប់រៀងខ្លួន។"

អត្ថបទដោយ៖ ណែម ឆាវ៉ាន់

ចម្លាក់ឈុតប្រយុទ្ធគ្នារវាងសុន្ទ និងឧបសុន្ទ នៅក្នុងសិល្បៈខ្មែរ គេមិនធ្លាប់ឃើញមាននៅសម័យមុនអង្គរ (ស.វ.ទី៧-៨) ឡើយ តែចាប់ផ្ដើមឃើញច្បាស់លាស់នៅស.វ.ទី១០ ក្នុងរចនាបថបន្ទាយស្រី ដែលសិល្បករបុរាណឆ្លាក់នៅលើហោជាងខាងលិចនៃគោបុរខាងកើតរបស់កំពែងទី៣នៃប្រាសាទបន្ទាយស្រី ខេត្តសៀមរាប (សព្វថ្ងៃហោជាងនេះរក្សាទុកនៅសារមន្ទីរហ្គីមេត៍ ប្រទេសបារាំង) (រូបលេខ១)។ ហោជាងនេះបង្ហាញតួអង្គភេទប្រុសពីរនាក់ កាន់ដំបង ហើយទាញដៃតួអង្គស្រីម្នាក់។ អ្នកស្រាវជ្រាវប្រវត្តិសិល្បៈខ្មែរជាច្រើនរូបឯកភាពគ្នា កំណត់អត្តសញ្ញាណរូបនេះថា តួអង្គប្រុសទាំងពីរ គឺជាសុន្ទ និងឧបសុន្ទ ហើយតួអង្គស្រីគឺជានាងតិលោត្តមា។ ហោជាងនេះ គឺឆ្លាក់សកម្មភាពចំនួនពីរផ្សេងគ្នា ដែលទី១ គឺបង្ហាញពីសកម្មភាពសុន្ទ និងឧបសុន្ទដណ្ដើមគ្នាយកនាងតិលោត្តមា អមសងខាងដោយតួអង្គរងផ្សេងទៀតអង្គុយមើល និងទីពីរបង្ហាញពីសកម្មភាពប្រយុទ្ធគ្នារវាងសុន្ទនិងឧបសុន្ទឆ្លាក់នៅផ្នែកខាងលើនៃហោជាង។

នៅមុនហោជាងប្រាសាទបន្ទាយស្រីបន្តិច ក្នុងតំបន់កោះកេរដែលមានអាយុកាលមុនរចនាបថបន្ទាយស្រីបន្តិចនោះ គេរកឃើញហោជាងមួយនៅប្រាសាទធំ ប៉ុន្តែចម្លាក់នេះបាត់បង់ផ្នែកពាក់កណ្ដាលខាងលើ (រូបលេខ២) ដែលជាហេតុនាំឱ្យយើងពិបាកក្នុងការកំណត់តួអង្គ និងសាច់រឿងឱ្យបានច្បាស់លាស់ណាស់។ ក្នុងនោះដែរ លោក Eric Bourdonneau យល់ថា ចម្លាក់នេះអាចជាឈុតរាក្សសវិរាធ ដែលនិយាយពីការពង្រាត់នាងសិតាពីព្រះរាម ក្នុងរឿងរាមាយណ ហើយក៏អាចជាឈុតសុន្ទនិងឧបសុន្ទប្រយុទ្ធគ្នាដើម្បីដណ្ដើមនាងតិលោត្តមាដែរ។ ប្រសិនបើមើលជាទូទៅ យើងឃើញថា ចម្លាក់នេះមានលក្ខណៈស្រដៀងនឹងចម្លាក់នៅហោជាងប្រាសាទបន្ទាយស្រីច្រើន ពោល គឺនៅកណ្ដាលមានតួអង្គធំៗចំនួនបីនាក់ និងនៅសងខាងមានមនុស្សពីរនាក់អង្គុយទស្សនា ដែលមើលហាក់ដូចជាសុន្ទ និងឧបសុន្ទដណ្ដើមនាងតិលោត្តមាដូច្នោះដែរ។ ម្ល៉ោះហើយ ប្រសិនបើចម្លាក់នៅកោះកេរនេះពិតជាបង្ហាញអំពីសាច់រឿងនេះមែន វាមានន័យថា ការបង្ហាញឈុតសុន្ទ និងឧបសុន្ទប្រយុទ្ធគ្នា គឺប្រហែលបង្ហាញឡើងដំបូងនៅក្នុងសិល្បៈខ្មែរនៅស.វ.ទី១០ ក្នុងរចនាបថកោះកេរ (គ.ស.៩២១ ដល់ ៩៤៤)។

យ៉ាងណាក៏ដោយ នៅស.វ.ទី១១ និងទី១២ ការបង្ហាញឈុតប្រយុទ្ធគ្នារវាងតួអង្គទាំងពីរដណ្ដើមនាងតិលោត្តមានេះ ក៏សិល្បករខ្មែរបុរាណនៅតែបន្តឆ្លាក់ដែរ។ ជាក់ស្ដែង នៅប្រាសាទបាភួនក្នុងតំបន់អង្គរ ដែលសាងឡើងនៅស.វ.ទី១១ ក្នុងរជ្ជកាលព្រះបាទឧទ័យទិត្យវរ្ម័នទី២ សិល្បករបានបង្ហាញឈុតនេះជាលក្ខណៈមួយបែបទៀតខុសពីនៅស.វ.ទី១០ ពោល គឺចម្លាក់បានបង្ហាញអំពីសុន្ទ និងឧបសុន្ទកំពុងប្រយុទ្ធគ្នាយ៉ាងស្វាហាប់ ហើយតួអង្គនាងតិលោត្តមាគឺ

អត្ថបទដោយ៖ ណៃម ធារ៉ាន់

អង្គុយនៅចំហៀង (រូបលេខ៣)។ ចំណែក នៅប្រាសាទធម្មនន្ទ ដែលសាងនៅស.វ.ទី១២ វិញ (រូបលេខ៤) សិល្បករបង្ហាញមួយបែបផ្សេងទៀតខុសពីរូបភាពទាំងបីដែលបានបង្ហាញខាងលើ គឺនាងតិលោត្តមាឆ្លាក់នៅកណ្ដាលដូចនៅហោជាងបន្ទាយស្រីដែរ តែសិល្បករឆ្លាក់ខ្ពស់ផុតទៅលើខ្លាំងពីតួអង្គសុន្ទ និងឧបសុន្ទ ដែលកំពុងប្រយុទ្ធគ្នា ហើយក៏មានតួអង្គរងអង្គុយទស្សនាការប្រយុទ្ធនេះផង។ យើងសង្កេតឃើញថា បើទោះបីសុន្ទ និងឧបសុន្ទ គឺជាតួអង្គតំណាងអសុរក៏ដោយ សិល្បករខ្មែរបានឆ្លាក់មុខមាត់ពួកគេក្នុងទម្រង់មុខដូចទេពឬដូចមនុស្សច្រើនជាងមុខជាយក្ស លើកលែងតែចម្លាក់នៅប្រាសាទធម្មនន្ទ ដែលមុខមាត់ពួកគេទាំងពីរបង្ហាញឡើងក្នុងទម្រង់កាចសាហាវដូច តួអង្គអសុរផ្សេងទៀតដែលយើងធ្លាប់ឃើញមាននៅក្នុងសិល្បៈខ្មែរ។

ជារួមមក សុន្ទ និងឧបសុន្ទ គឺជាតួអង្គក្នុងរឿងមហាភារតដែលរៀបរាប់អំពីបងប្អូនពីរនាក់ជាអសុរមានមហិទ្ធិឫទ្ធិខ្លាំងពូកែប្រយុទ្ធគ្នាដណ្ដើមយកនាងតិលោត្តមា។ ឈុតនេះមានបង្ហាញនៅក្នុងសិល្បៈខ្មែរដំបូងនៅក្នុងស.វ.ទី១០ ហើយមានឆ្លាក់បង្ហាញបន្តនៅស.វ.ទី១១ និងទី១២។ ទោះបីជាយ៉ាងណា ចម្លាក់តួអង្គសុន្ទ និងឧបសុន្ទ ដែលបង្ហាញនៅលើចម្លាក់តាមប្រាសាទបុរាណរបស់ខ្មែរគេពុំអាចកំណត់ថា ម្នាក់ណាជាសុន្ទ និងម្នាក់ជាឧបសុន្ទឱ្យបានច្បាស់បានឡើយ ដ្បិតអ្នកទាំងពីរបង្ហាញឡើងក្នុងមុខមាត់និងរូបរាងដូចគ្នា ហើយកាន់កេតនភណ្ឌក៏ដូចគ្នាទៀត។

## ឯកសារយោង


Baptiste, P. & Zéphir, T. 2008. *L'Art Khmer dans les collections du musée Guimet,* Paris.

Bourdonneau, É. 1999, Redéfinir l'originalité de Banteay Srei : relation entre iconographie et architecture. Aséanie 3, pp. 27-65.

Bourdonneau, É. 2011, Nouvelles recherches sur Koh Ker (Chok Gargyar). Jayavarman IV et la maîtrise des mondes. Monuments et mémoires de la Fondation Eugène Piot, tome 90, pp. 95-141.

Roveda, V. 2005, *Images of the Gods*, Riverbook, Bangkok.


អត្ថបទដោយ៖ ណែម ឆាវ៉ាន់



រូបលេខ១៖ ចម្លាក់បង្ហាញអំពីសុន្ទ និងឧបសុន្ទប្រយុទ្ធគ្នាដណ្តើមនាងតិលោត្តមានៅហោជាង
ប្រាសាទបន្ទាយស្រី ((សព្វថ្ងៃរក្សាទុកនៅសារមន្ទីរហ្គីមេត៍ ប្រទេសបារាំង)



រូបលេខ២៖ ប្រហែលចម្លាក់បង្ហាញអំពីសុន្ទ និងឧបសុន្ទប្រយុទ្ធគ្នាដណ្តើមនាងតិលោត្តមានៅ
ហោជាងប្រាសាទធំ តំបន់កោះកេរ

អត្ថបទដោយ៖ ណៃម ធាវ៉ាន់



*រូបលេខ៣៖ ចម្លាក់បង្ហាញអំពីសុន្ទ និងឧបសុន្ទប្រយុទ្ធគ្នាដណ្ដើមនាងតិលោត្តមានៅជញ្ជាំងប្រាសាទ បាភួន តំបន់អង្គរ*



*រូបលេខ៤៖ ចម្លាក់បង្ហាញអំពីសុន្ទ និងឧបសុន្ទប្រយុទ្ធគ្នាដណ្ដើមនាងតិលោត្តមានៅហោជាង ប្រាសាទធម្មនន្ទ តំបន់អង្គរ (រូបភាព៖ លោក លួន ទីយា)*

*អត្ថបទដោយ៖ ណែម ធារ៉ាន់*